# សាររបស់រដ្ឋលេខាធិការ

អ្នកបោះឆ្នោត California ជាទីគោរព!

ការចូលរួមរបស់អ្នកនៅក្នុងដំណើរការបោះឆ្នោតនីមួយៗមានសារៈសំខាន់ណាស់ ដើម្បីធានាដល់ការរីកចម្រើនតាមបែបលទ្ធិប្រជាធិបតេយ្យ។ ក្នុងនាមជាអ្នកបោះឆ្នោតនៅរដ្ឋ California អ្នកនឹងមានឱកាសបោះឆ្នោតនៅក្នុង**ការបោះឆ្នោតពិសេសក្នុងរដ្ឋទាំងមូល**នាពេលខាងមុខនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2025។ ការបោះឆ្នោតនេះនឹងស្នើសុំឱ្យអ្នក**យល់ព្រម ឬបដិសេធ**សំណើបោះឆ្នោត។

អ្នកមានវិធីជាច្រើនក្នុងការចូលរួម ខណៈដែលរដ្ឋ California បន្តការពារ និងពង្រីកសិទ្ធិបោះឆ្នោតរបស់អ្នក។ យើងលើកកម្ពស់ការបោះឆ្នោតតាមសំបុត្រ មធ្យោបាយបោះឆ្នោតដោយផ្ទាល់ជាច្រើន ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងថ្ងៃតែមួយ និងការបោះឆ្នោតបណ្ដោះអាសន្ន ដែលទាំងអស់នេះត្រូវបានរៀបចំឡើងដើម្បីការពារ និងបង្កលក្ខណៈងាយស្រួលដល់ការបោះឆ្នោត។

មគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតនេះត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកធ្វើការសម្រេចចិត្តឱ្យបានគ្រប់ជ្រុងជ្រោយលើសំណើទី 50។ នៅក្នុងមគ្គុទ្ទេសក៍នេះ អ្នកនឹងរកឃើញព័ត៌មានលម្អិតសំខាន់ៗអំពីពេលវេលា ទីកន្លែង និងរបៀបគូសសន្លឹកឆ្នោតរបស់អ្នក ព្រមទាំងសេចក្ដីសង្ខេបខ្លះៗ និងការវិភាគអំពីវិធានការ។ មគ្គុទ្ទេសក៍នេះបង្ហាញពីទឡ្ហីករណ៍ផ្លូវការដែលគាំទ្រ និងប្រឆាំងនឹងសំណើទី 50 រួមជាមួយការបដិសេធ ដើម្បីឱ្យអ្នកអាចពិចារណាលើទស្សនៈជាច្រើន មុនពេលធ្វើការសម្រេចចិត្ត។

**មគ្គុទ្ទេសក៍របស់អ្នករួមបញ្ចូលៈ**

- សេចក្ដីសង្ខេបឯករាជ្យអំពីសំណើទី 50 ជាមួយនឹងទឡ្ហីករណ៍គាំទ្រ និងប្រឆាំង រួមទាំងព័ត៌មានទំនាក់ទំនងសម្រាប់អ្នកគាំទ្រ និងអ្នកប្រឆាំង។ (ទំព័រទី 5)
- ការណែនាំច្បាស់លាស់អំពីរបៀបបោះឆ្នោតតាមសំបុត្រ ដោយផ្ទាល់ ឬតាមរយៈប្រអប់ទម្លាក់សន្លឹកឆ្នោតសុវត្ថិភាព។ បន្ថែមពីនេះ សូមចងចាំចុះហត្ថលេខា និងបោះត្រាលើសន្លឹកឆ្នោតរបស់អ្នក។ (ទំព័រទី 7)
- ព័ត៌មានទាក់ទងនឹងការជូនដំណឹងអំពី**សន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា**តាមរយៈ *WheresMyBallot.sos.ca.gov*។
- ព័ត៌មានលម្អិតអំពីថ្ងៃបោះឆ្នោតបន្ថែម និងមណ្ឌលបោះឆ្នោតនៅក្នុងខោនធីតាមច្បាប់នៃជម្រើសរបស់អ្នកបោះឆ្នោតដែលអ្នកអាចចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃតែមួយបាន។ (ទំព័រទី 6)

ការចូលរួមក្នុងការបោះឆ្នោតគឺមានសារៈសំខាន់ ដើម្បីបញ្ចេញមតិចំពោះការសម្រេចចិត្តដែលមានឥទ្ធិពលមកលើជីវិតរបស់យើង និងរបៀបដែលសហគមន៍របស់យើងដំណើរការ។ ខ្ញុំសូមលើកទឹកចិត្តឱ្យអ្នកចំណាយពេលស្វែងយល់អំពីបញ្ហា និងឥទ្ធិពលនៃការបោះឆ្នោតនេះ ហើយបន្ទាប់មកធ្វើការសម្រេចចិត្ត។ ការបោះឆ្នោតមានន័យថា សំឡេងរបស់អ្នកនឹងត្រូវបានគេឮ ហើយអ្នកមានសិទ្ធិបញ្ចេញមតិនាពេលអនាគត។

សូមអរគុណចំពោះការរក្សាលទ្ធិប្រជាធិបតេយ្យរបស់យើងឱ្យបានរឹងមាំ!